# ចេរភាពចំហាយសំរាប់ រោងចក្រកាត់ដេរកម្ពុជា

## ដុំអង្កាមពូត ប្រឆាំងនិងការកាប់បំផ្លាញព្រៃឈើ និងការប្រែប្រួលអាកាសធាតុ





ចេរភាពថាមពលកំដៅ និងជីវម៉ាស់ជំនួស

geres

# បញ្ហាអុស

## នៅក្នុងវិស័យកាត់ដេរកម្ពុជា



អុសជាង **300,000** តោន ត្រូវបានដុតជារៀងរាល់ឆ្នាំ ដោយរោងចក្រកាត់ដេរ

ព្រៃឈើទំហំស្មើ **5,000** នៃវាលបាល់ទាត់ បានប្រើប្រាស់ជារៀងរាល់ឆ្នាំ

"...ហើយ **368,000** តោន នៃឧស្ម័នកាបូនិច បំភាយជារៀងរាល់ឆ្នាំ"

**បច្ចុប្បន្ន អុសជាង 780 000 តោនត្រូវបានដុតជារៀងរាល់ឆ្នាំ ដោយវិស័យឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជា ដើម្បីផលិតកំដៅ និងចំហាយ ក្នុងនោះ គ្រាន់តែវិស័យកាត់ដេរដុតអស់យ៉ាងហោចណាស់ 300 000 តោន** ដែលភាគច្រើនគឺសំរាប់ អ៊ុត បោកគក់ និងជ្រលក់ពណ៌។ វាត្រូវបានគេប៉ាន់ប្រមាណថាអុស **70%** មានប្រភពមកពីការកែប្រែដីព្រៃទៅជាដីកសិកម្ម ឬក៏ការប្រមូលផលខុសច្បាប់ដែលចូលរួមចំណែកក្នុងការកាប់បំផ្លាញព្រៃឈើ និងនាំអោយមានការប្រែប្រួលអាកាសធាតុ។ តួលេខនេះតំណាងអោយការបំភាយនៃឧស្ម័នកាបូនិកចំនួន **368 000** តោន ក្នុងមួយឆ្នាំ ដែលស្មើនឹងព្រៃចំនួន **3500** ហិកតាជារៀងរាល់ឆ្នាំ។

**រហូតដល់ឆ្នាំ 2035 វានឹងមិនមានអុសដុតគ្រប់គ្រាន់ពីឈើដាំដុះ ដើម្បីបំពេញតម្រូវការរបស់ឧស្សាហកម្ម។ ប្រសិនបើគ្មានការផ្លាស់ប្តូរ ទេនោះអុសព្រៃដែលអចេរភាពជាច្រើន នឹងត្រូវប្រើប្រាស់ដើម្បីបំពេញចន្លោះនោះ។**

ជាមួយនិងការកើនឡើងនៃតំរូវការ អុស **វានាំអោយមានសម្ពាធកាន់តែខ្លាំងលើ ធនធានព្រៃធម្មជាតិ។** នឹងនាំអោយមានការកើនឡើងនៃតំលៃអុស ហើយប្រឈមនិងហានិភ័យកាន់តែធំឡើង ដែលមានពីប្រភពអុសខុសច្បាប់ និងព្រៃការពារថែមទៀត។

សព្វថ្ងៃនេះ **តម្រូវការរបស់ឧស្សាហកម្មតែ 30% ប៉ុណ្ណោះដែលអាច** បំពេញដោយដំណាំអុសស្វាយចន្ទី និងអុសកៅស៊ូ។



# ហេតុអ្វីបានជាអ្នកផ្គត់ផ្គង់សំលៀកបំពាក់ត្រូវធ្វើសកម្មភាពលើការប្រែប្រួលអាកាសធាតុ ?

## បញ្ហាប្រឈមសកលចំពោះវិស័យផ្សេងៗនៃសេដ្ឋកិច្ច

ការប្រែប្រួលអាកាសធាតុ គឺអាចមានការគំរាមកំហែង ដ៏ធ្ងន់ធ្ងរចំពោះសេដ្ឋកិច្ច សុខុមាលភាពរបស់ប្រជាជននៅក្នុងប្រទេសកម្ពុជា និងទូទាំងពិភពលោក។ វាជាបុព្វហេតុចម្បង ដោយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលបង្ករអោយមានការកើនកំដៅផែនដី និងបង្កើនការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃទឹកជំនន់ ភាពរាំងស្ងួតខ្យល់ព្យុះនិងទឹកសមុទ្រជាលំដាប់។ ផលិតភាពនៃវិស័យសេដ្ឋកិច្ចជាច្រើននឹងត្រូវរងការប៉ះពាល់ជាទម្ងន់ ដោយសារការផ្លាស់ប្តូរទាំងនេះ។

ព្រៃធម្មជាតិផ្ទុកឧស្ម័នការបូនិចពីបរិយាកាស។ ការដុតអុសព្រៃដែលគ្មានការគ្រប់គ្រងដោយចេរភាព បំភាយឧស្ម័នកាបូនិចចូលទៅក្នុងបរិយាកាស ដូច្នេះវាចូលរួមធ្វើអោយមានការប្រែប្រួលអាកាសធាតុ។




ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់កាកសំណល់កសិកម្មផ្សេងៗ ដូចជា អង្កាម អាចចាត់ទុកជាសមតុល្យកាបូន ដោយហេតុថាឧស្ម័នកាបូនិចដែលបំភាយក្នុងកំឡុងពេលចំហេះ គឺត្រូវបានស្រូបឡើងវិញដោយដំណាំដែលដាំដុះនៅរដូវក្រោយជារៀងរាល់ឆ្នាំ។

> “វត្ថុបំណងរបស់យើងគឺដើម្បីសម្រេចនូវចង្វាក់ផ្គត់ផ្គង់តុល្យភាពអាកាសធាតុនៅត្រឹមឆ្នាំ 2030។ គោលដៅមួយក្នុងគោលដៅដ៏ធំរបស់យើងគឺ ដើម្បីកាត់បន្ថយអោយបាន 30% នៃការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងផលិតផលមួយនៅឆ្នាំ 2025”
>
> **Aurelie Pruvost**, H&M,
> អ្នកទទួលបន្ទុកផ្នែកកម្មវិធីនិរន្តរភាពបរិស្ថានប្រចាំប្រទេស កម្ពុជា និងវៀតណាម

## រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាកំពុងជំរុញឆ្ពោះទៅរកការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់

នៅក្នុងក្របខ័ណ្ឌនៃ កិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយនិងការព្រួយបារម្ភ កាន់តែច្រើនឡើង អំពីការប្រែប្រួលអាកាសធាតុ និងការកាប់បំផ្លាញព្រៃឈើ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តផែនការយុទ្ធសាស្ត្ររបស់ខ្លួន ស្តីអំពីការប្រែប្រួលអាកាសធាតុសំរាប់ឆ្នាំ 2014-2023 រួមមាន វិធានការនានា ដើម្បីអោយស្ថាប័នជំនួញ អង្គការមិនមែនរដ្ឋាភិបាល រដ្ឋបាលសាធារណៈ និងសហគមន៍មានលទ្ធភាព ដើម្បីឆ្លើយតបទៅនិងបញ្ហាប្រែប្រួលអាកាសធាតុតាមរយៈការអនុវត្តន៍សកម្មភាពនានា ក្នុងការបន្ធូរបន្ថយ។

## ក្រុមហ៊ុនបញ្ជាទិញអន្តរជាតិ តម្រូវអោយមានចង្វាក់ផ្គត់ផ្គង់ បៃតង

បណ្តាក្រុមហ៊ុនសំលៀកបំពាក់អន្តរជាតិ ក៏កំពុងតែជំរុញឆ្ពោះទៅរកការកាត់បន្ថយ ការបំភាយឧស្ម័នផ្ទះកញ្ចក់ផងដែរ។ ក្នុងនោះក្រុម H&M បានកំណត់ទិសដៅអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ ដែលនាំអោយមានការផ្លាស់ប្តូររបស់ខ្លួនឆ្ពោះទៅរកសង្វាក់ផ្គត់ផ្គង់សមតុលកាបូន ដោយជំរុញអោយប្រើប្រាស់ប្រសិទ្ធភាពថាមពល និង ថាមពលកកើតឡើងវិញ។

**-7%** by 2030

គោលដៅរបស់រដ្ឋាភិបាលកម្ពុជាគឺដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់អោយបាន7% នៅក្នុងប្រទេស (ប្រៀបធៀបទៅនឹងឆ្នាំ 2010)។

# ហេតុអ្វីមានការប្រើប្រាស់ ដុំអង្កាមពូតទាំងនេះ?

**ដុំអង្កាមពូត (RHB) គឺជាឥន្ធនៈមួយ ថោកជាងគេសំរាប់ការផលិតចំហាយ ហើយវាមានការបំភាយឧស្ម័ន តិចជាងគេ។**




## ដុំអង្កាមពូតមាន ពីរប្រភេទ

មានដុំអង្កាមពូតពីរប្រភេទ ដុំអង្កាមពូតប្រភេទ ពីស្តុង និងដុំអង្កាមពូតប្រភេទស្គ្រូ។ តាមធម្មតាប្រភេទអង្កាមពូតស្គ្រូគឺ ណែនជាង ធំជាង និងដុតបានយូរ ហើយប្រភេទស្គ្រូនេះគឺមានតម្លៃថ្លៃផងដែរ ព្រោះផលិតផលនេះត្រូវប្រើថាមពលអគ្គិសនីច្រើន។ ប្រភេទអង្កាមពូតពីស្តុង គឺធម្មតាថោកជាង។ ទោះបីយ៉ាងណាក៏ដោយ ដុំនេះមិនសូវណែន និងងាយបែកដូចដែលវាមិនសូវមានភាពរឹងគ្រប់គ្រាន់។ ប៉ុន្តែពួកវាទាំងពីរប្រភេទ មានតម្លៃថាមពលកំដៅ និងសំណើមដូចគ្នា។



អង្កាមពូតពីស្តុង *



អង្កាមពូតស្គ្រូ *

## ដុំអង្កាមពូតវាងាយស្រួលជំនួសអុសបាន

ដុំអង្កាមពូតអាចប្រើបានស្ទើរតែគ្រប់ឡចំហាយទាំងអស់ដែលដុតអុស(ដោយគ្រាន់តែធ្វើការកែឡៃថេងតិចតួចនៅក្នុងបន្ទប់ចំហេះប៉ុណ្ណោះដើម្បីកុំអោយផេះកកនៅដែលនាំអោយស្ទះខ្យល់)។ សូមសួរទៅម្ចាស់រោងចក្រផលិតឡចំហាយរបស់អ្នកប្រសិនបើអ្នកត្រូវការកែប្រែ។

## អាចដុតលាយជាមួយអុសបាន

ប្រសិនបើចាំបាច់គឺអាចប្រើដុំអង្កាមពូតជំនួសអុសឬក៏អាចដុតលាយគ្នាបាននៅក្នុងបន្ទប់ចំហេះ។

*ដោយ៖ C.F Nielsen

## អង្កាមពូតមានប្រសិទ្ធភាពជាងអុស

ដុំអង្កាមពូតតាមធម្មតា មានប្រសិទ្ធភាពជាងអុស អរគុណច្រើនចំពោះចំណើមទាបរបស់វា។ ដុំអង្កាមពូតតែងតែមានសំណើមថេរទាបជាង 10% ខណៈពេលដែលអុសមានសំណើមពី 20% ទៅ 40%។ សំណើមកាត់បន្ថយតម្លៃថាមពលកំដៅនៃឥន្ធនៈយ៉ាងច្រើន។

## ជាដំណោះស្រាយមួយ ដែលបានប្រើពេញប្រទេសអាស៊ី

ដុំអង្កាមពូតត្រូវបានបណ្តាប្រទេសជាច្រើន បាននិងកំពុងប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មខុសៗគ្នា ដែលត្រូវការចំហាយក្នុងដំណើរការផលិតកម្មរបស់ខ្លួន ជាពិសេសបណ្តាប្រទេសដែលមិនសូវមានអុសដូចប្រទេសកម្ពុជា។

## អង្កាមគឺមានគ្រប់ពេញមួយឆ្នាំ

1.5 លានតោននៃអង្កាមគឺត្រូវបានផលិតជារៀងរាល់ឆ្នាំនៅក្នុងប្រទេសកម្ពុជា ចាប់ពីខែមករាដល់ខែធ្នូ គឺវាមានច្រើនជាងអ្វីដែលឧស្សាហកម្មត្រូវការ។

## ងាយស្រួលក្នុងការរក្សាទុក និង ដឹកជញ្ជូន

ដុំអង្កាមពូតត្រូវបានផលិតដោយការគៀបបំណែនអង្កាមទៅជាដុំរាងស៊ីឡាំងដើម្បីបង្កើនមុខងារចំហេះកាត់បន្ថយតំលៃក្នុងការទុកដាក់និងការដឹកជញ្ជូន។

# ប្រសិទ្ធភាព ថាមពល

## ការអនុវត្តល្អដើម្បី សន្សំលុយនិងថាមពល



### រក្សាអុសទុកនៅកន្លែងស្ងួត

កំរិតសំណើមខ្ពស់វាកាត់បន្ថយប្រសិទ្ធភាពឥន្ធនៈជីវម៉ាស់យ៉ាងធ្ងន់ធ្ងរ អុសដែលមានកំរិតសំណើម 40% មានប្រសិទ្ធភាព 30% ទាបជាង អុសដែលមានកំរិតសំណើម 20%។ រឿងនេះត្រូវតែគិតពេលទិញឥន្ធនៈជីវម៉ាស់ (អុស) និងការទុកដាក់វានៅក្នុងរោងកុំអោយត្រូវភ្លៀង។



### ការត្រួតពិនិត្យក្នុង ការប្រើប្រាស់ថាមពល

ការចាត់វិធានការទៅលើការប្រើប្រាស់ថាមពលគឺជាជំហ៊ានដំបូងបង្អស់ មុននឹងធ្វើការសំរេចចិត្តអោយបានត្រឹមត្រូវទៅលើ( ការវិនិយោគទៅលើឡចំហាយថ្មី ការផ្លាស់ប្តូរទៅប្រើឥន្ទនៈថ្មី )។



### ការកែលំអប្រព័ន្ធចំហាយ ហើយជួសជុលវា

រោងចក្រជាច្រើននៅក្នុងប្រទេសកម្ពុជាមានចំណុចខ្វះខាតក្នុងប្លង់របស់ប្រព័ន្ធ និងការតំឡើងប្រព័ន្ធចំហាយរបស់ខ្លួន។ វាគឺជារឿងសំខាន់ក្នុងការដែលធ្វើអោយប្រាកដថាប្រព័ន្ធចំហាយត្រូវបានតំឡើងដោយត្រឹមត្រូវ ហើយឧបករណ៍ទាញទឹកចេញពីចំហាយមិនខូចខាត( steam traps or separator ) បំពង់ចំហាយត្រូវរុំអ៊ីសូឡង់អោយបានជិតល្អ ហើយត្រូវត្រួតពិនិត្យថែទាំប្រព័ន្ធអោយបានទៀងទាត់។ ការវិនិយោគទៅលើប្រព័ន្ធត្រឹមត្រូវក្នុងការប្រើប្រាស់កំណកចំហាយសល់ឡើងវិញគឺជារឿងសំខាន់។



### ប្រើឡចំហាយដែលមានប្រសិទ្ធភាព

ប្រមាណ 40% នៃឡចំហាយដែលប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាមានប្រសិទ្ធភាពក្រោម 40%។ ការផ្លាស់ប្តូរទៅប្រើឡចំហាយ ដែលមានប្រសិទ្ធភាព 80% ជាធម្មតាផ្តល់នូវការសន្សំយ៉ាងច្រើននិងបានទទួលដើមទុនត្រឡប់មកវិញក្នុងរយៈពេលខ្លី ( តិចជាង 2 ឆ្នាំ )។



# ថាមពលកំដៅដែលមានចីរភាព និងការជំនួសដោយជីវម៉ាស់

គំរោង ចំហាយ

**តាំងពីខែមិថុនាឆ្នាំ2016 អង្គការ GERES ដោយមានការគាំទ្រពី H&M និងសម្ព័ន្ធប្រែប្រួលអាកាសធាតុកម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវរកដំណោះស្រាយក្នុងការកាត់បន្ថយការប្រើប្រាស់អុសអចីរភាពនៅក្នុងផលិតកម្មឧស្សាហកម្ម។**

កិច្ចសហប្រតិបត្តិការណ៍ និងការផ្តល់មតិគ្នាទៅវិញទៅមករវាង រោងចក្រកាត់ដេរ និងសិប្បកម្មរោងម៉ាស៊ីនស្រូវបានផ្តល់លទ្ធភាពអោយអង្គការជើរ៉េស(GERES) រកដំណោះស្រាយសមស្របមួយ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីរោងចក្រជាច្រើន ទៅលើការប្រែប្រួលអាកាសធាតុ និងការកាប់បំផ្លាញព្រៃឈើ។ អង្គការជើរ៉េស បានសាកល្បងធ្វើពិសោធន៍ជាច្រើនដង នៅក្នុងមន្ទីរពិសោធន៍ និងតាមរោងចក្រនានា ដើម្បីបញ្ជាក់ប្រាប់អំពីបច្ចេកទេសដែលអាចប្រើប្រាស់បាន និងលទ្ធផលនៃការប្តូរពីការដុតអុសព្រៃទៅដុតដុំអង្កាមពូត ដើម្បីផលិតចំហាយនៅក្នុងប្រទេសកម្ពុជា។


ក្រុមថាមពលកកើតឡើងវិញ បរិស្ថាន និងសាមគ្គីភាព
ការិយាល័យប្រចាំតំបន់អាស៊ីអគ្នេយ៍

ការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍ អាគារ #7B (ជាន់ទី3)
ផ្លូវលេខ81 កែងនិងផ្លូវលេខ109 សង្កាត់បឹងរាំង
ខណ្ឌដូនពេញ ទីក្រុងភ្នំពេញ កម្ពុជា

អ៊ីមែល: **contact@geres.eu**

ទូរស័ព្ទ: +855 78 767 499 / +855 16 600 617


សំរាប់ព័ត៌មានបន្ថែមសូមមើលគេហទំព័រ
**www.geres.eu**


CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, SWEDEN

WISIONS of sustainability

H&M